


# ក្រមសីលធម៌

## គោលការណ៍ក្រមសីលធម៌របស់ BOS Group

ផ្តោតលើអតិថិជន

-ជំរុញដោយនវានុវត្តន៍

# តារាងមាតិកា


**គោលបំណងនៃក្រមសីលធម៌ ៣**

**១. សេចក្តីផ្តើម ៤**

១.១ គោលបំណងនៃក្រមសីលធម៌ របស់ BOS Group ៤

១.២ មូលដ្ឋានគ្រឹះ ៤

**២. សិទ្ធិមនុស្ស លក្ខខណ្ឌការងារ និងទ្រព្យសម្បត្តិ ៥**

២.១ ការទទួលខុសត្រូវផ្ទាល់ខ្លួន ៥

២.២ ឱកាសស្មើគ្នា/ការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌/កិច្ចការពារប្រឆាំងនឹងការរើសអើង ៥

២.៣ លក្ខខណ្ឌការងារត្រឹមត្រូវ ៦

- ការហាមឃាត់ពលកម្មកុមារ
- ការហាមឃាត់ពលកម្មដោយបង្ខំ/ ជ្រើសរើសការងារដោយសេរី
- សេរីភាពនៃសមាគម និងសិទ្ធិចរចាជាសមូហភាព
- ប្រាក់លាភការ ម៉ោងធ្វើការ និងគុណវុឌ្ឍិ

២.៤ កិច្ចគាំពារសុខភាព សុវត្ថិភាព និងបរិស្ថាននៅកន្លែងធ្វើការ ៧

២.៥ ការចៀសវាងនូវទំនាស់ផលប្រយោជន៍ ៧

២.៦ ការការពារទ្រព្យសម្បត្តិក្រុមហ៊ុន ៧

២.៧ សុវត្ថិភាពព័ត៌មាន និងការការពារទិន្នន័យ ៨

២.៨ សិទ្ធិជនជាតិភាគតិច និងជនជាតិដើមភាគតិច / សិទ្ធិដីធ្លី ៨

**៣. អន្តរកម្មជាមួយដៃគូអាជីវកម្ម ៩**

៣.១ ការជ្រើសរើសដៃគូអាជីវកម្ម ៩

៣.២ ការប្រកួតប្រជែងដោយយុត្តិធម៌ និងនិរន្តរភាព ៩

៣.៣ ធនធានរ៉ែមានទំនាស់ ១០

៣.៤ ការប្រកួតប្រជែង និងច្បាប់ប្រកួតប្រជែងដោយយុត្តិធម៌ ១០

៣.៥ ការជូនកាដូ និងអត្ថប្រយោជន៍ ១០

៣.៦ អំណោយ ១០

**៤. ភាពអនុលោម និងការអនុវត្តក្រមសីលធម៌ ១១**

៤.១ ការទទួលខុសត្រូវ ១១

៤.២ ការរំលោភបំពាន ១១

៤.៣ បុគ្គលទំនាក់ទំនង ១២

៤.៤ ការស៊ើបអង្កេត និងការរាយការណ៍ ១២

**៥. ប្រការចុងក្រោយ ១៣**

# គោលបំណងនៃក្រមសីលធម៌

អូសទ្វីឌើន ខែមីនា ២០២៣

## ជូនចំពោះនិយោជិតជាទីរាប់អាន៖

BOS Group គឺជាក្រុមហ៊ុនដែលកំពុងប្រតិបត្តិការនៅទូទាំងពិភពលោក។ ក្រមសីលធម៌ជាមួយនឹងវិធាន និងគោលការណ៍របស់ខ្លួនផ្តល់នូវការណែនាំដែលយើងដំណើរការ។ ក្រមសីលធម៌របស់ BOS ពឹងផ្អែកភាគច្រើនទៅលើគោលការណ៍ទាំងដប់នៃកិច្ចព្រមព្រៀងសាកលរបស់អង្គការសហប្រជាជាតិ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស និងគោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិសាសន៍។ ក្រមសីលធម៌នេះកំណត់ស្តង់ដារខ្ពស់នៅក្នុង BOS Group ទាក់ទងនឹងនិយោជិត ដៃគូខាងក្រៅ និងបរិស្ថានរបស់យើង។

ការអនុលោមតាមច្បាប់ ការប្រកាន់ខ្ជាប់នូវបទបញ្ជាផ្ទៃក្នុង និងការគោរពតម្លៃសីលធម៌ជាមូលដ្ឋានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង (អនុលោមភាព) គឺជាមូលដ្ឋាននៃភាពជោគជ័យផ្នែកសេដ្ឋកិច្ចរបស់យើង។ ក្រមសីលធម៌នេះបម្រើដល់ពួកយើងទាំងអស់គ្នាជាក្របខ័ណ្ឌនៃការតម្រង់ទិសសម្រាប់ការងារប្រចាំថ្ងៃរបស់យើង មិនថាជាថ្នាក់ដឹកនាំ ឬនិយោជិតនោះទេ។ ក្រមសីលធម៌នេះកំណត់ស្តង់ដារសម្រាប់យើងម្នាក់ៗ និងស្របពេលជាមួយគ្នានេះដែរ ក៏ជួយឲ្យយើងមានអាកប្បកិរិយាទទួលខុសត្រូវចំពោះដៃគូអាជីវកម្មរបស់យើង សាធារណជន និងសហការីទាំងអស់។ យើងក៏រំពឹងថា ដៃគូអាជីវកម្ម និងអ្នកផ្គត់ផ្គង់របស់យើងនឹងមានអាកប្បកិរិយាទទួលខុសត្រូវចំពោះពួកយើងផងដែរ។ យើងទទួលខុសត្រូវរួមគ្នាចំពោះកេរ្តិ៍ឈ្មោះរបស់ BOS។

ដូច្នេះ យើងសូមស្នើសុំឲ្យលោកអ្នកដែលជានិយោជិតទាំងអស់គោរពក្រមសីលធម៌ដោយយកចិត្តទុកដាក់ និងប្រើប្រាស់វាជាគោលការណ៍ណែនាំសម្រាប់អនុវត្តការងារប្រចាំថ្ងៃរបស់យើង។

Marcel Lehmann
ប្រធានក្រុមហ៊ុន

## ១. សេចក្តីផ្តើម

### ១.១ គោលបំណងនៃក្រមសីលធម៌ របស់ BOS Group

វាជាការកិច្ចរបស់យើងក្នុងការធ្វើប្រតិបត្តិការអាជីវកម្មទាំងអស់ប្រកបដោយសីលធម៌ និងត្រឹមត្រូវតាមច្បាប់ ក្នុងគោលបំណងបង្កើតបរិយាកាសនៃការជឿទុកចិត្តគ្នាទៅវិញទៅមកជាមួយដៃគូអាជីវកម្មរបស់យើង ក៏ដូចជាសហការីរបស់យើងនៅខាងក្នុងក្រុមហ៊ុន។ យើងយល់ឃើញថា នេះជាមូលដ្ឋានគ្រឹះដើម្បីធ្វើឲ្យមានវិបុលភាព និងភាពជោគជ័យយូរអង្វែង។

BOS Group ប្តេជ្ញាគោរពសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ យើងក៏រំពឹងផងដែរថាដៃគូអាជីវកម្មរបស់យើងនឹងប្រកាន់ខ្ជាប់នូវសិទ្ធិមនុស្ស ជាពិសេស កិច្ចព្រមព្រៀងជាសាកលរបស់អង្គការសហប្រជាជាតិ និងធ្វើការយ៉ាងសកម្មឆ្ពោះទៅរកអនុលោមភាព និងការអនុវត្តគោលការណ៍ទាំងនេះស្របតាមខ្សែសង្វាក់តម្លៃ។

### ១.២ មូលដ្ឋានគ្រឹះ

កេរ្តិ៍ឈ្មោះល្អ និងការជឿទុកចិត្តរបស់អតិថិជន និយោជិត និងសាធារណជនភាគច្រើនពឹងផ្អែកទៅលើអាកប្បកិរិយារបស់បុគ្គលម្នាក់ៗនៅក្នុងក្រុមហ៊ុននេះ។ ដូច្នេះ និយោជិតម្នាក់ៗត្រូវមានការទទួលខុសត្រូវស្មើគ្នាក្នុងការប្រកាន់ខ្ជាប់នូវគុណតម្លៃ និងគោលបំណងរបស់ក្រុមហ៊ុន និងធ្វើទៅតាមផ្នែកនៃការទទួលខុសត្រូវរៀងៗខ្លួន។ ដូច្នេះ យើងត្រូវការវិធាន និងគោលការណ៍ណែនាំដែលត្រឹមត្រូវ។

ក្រមសីលធម៌បច្ចុប្បន្ននេះសង្ខេបអំពីវិធាន និងគោលការណ៍ណែនាំដ៏សំខាន់បំផុតដែលនិយោជិតរបស់ BOS ទូទាំងពិភពលោកគួរអនុវត្តតាម។ គោលការណ៍ដែលបានពន្យល់នៅក្នុងឯកសារនេះអនុវត្តនៅក្នុងអន្តរកម្មជាមួយសហការី អតិថិជន អ្នកផ្គត់ផ្គង់ ដៃគូអាជីវកម្ម និងស្ថាប័នសាធារណៈទូទាំងពិភពលោកនៅគ្រប់ទីតាំង និងសម្រាប់អង្គភាពអាជីវកម្មទាំងអស់របស់ BOS Group។

យើងរំពឹងថា និយោជិតទាំងអស់មិនត្រឹមតែអនុវត្តតាមបទបញ្ជាផ្ទៃក្នុងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគោរពច្បាប់ដោយគ្មានការលើកលែង ចៀសវាងទំនាស់ផលប្រយោជន៍ ការពារទ្រព្យសម្បត្តិរបស់ BOS និងលើកស្ទួយប្រពៃណី និងគុណតម្លៃរបស់បណ្តាប្រទេសដែលយើងមានទំនាក់ទំនងអាជីវកម្មជាមួយ។

យើងរំពឹងទុកពីបុគ្គលិកគ្រប់គ្រងរបស់យើងក្នុងការបំពេញតួនាទីជាគំរូ ដែលក្នុងនោះពួកគាត់មិនត្រឹមតែយល់ដឹងពីវិធានទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដឹកនាំជាគំរូ និងអំពាវនាវឲ្យនិយោជិតរបស់ខ្លួនអនុវត្តតាមទៀតផង។ ពួកគាត់គឺជាបុគ្គលទំនាក់ទំនងដំបូងសម្រាប់ឆ្លើយរាល់សំណួរ និងក្តីកង្វល់ទាំងអស់ទាក់ទងនឹងក្រមសីលធម៌នេះ។

## ២. សិទ្ធិមនុស្ស លក្ខខណ្ឌការងារ និងទ្រព្យសម្បត្តិ

យើងជឿជាក់ថា ភាពជោគជ័យប្រកបដោយនិរន្តរភាពនៃអាជីវកម្មជាលក្ខណៈគ្រួសាររបស់យើងពឹងផ្អែកយ៉ាងខ្លាំងទៅលើវប្បធម៌ក្រុមហ៊ុនផ្តោតលើតម្លៃ និងនិយោជិតម្នាក់ៗរួមចំណែកយ៉ាងសំខាន់ដើម្បីធ្វើឲ្យក្រុមហ៊ុនទទួលបានភាពជោគជ័យ។ យើងកំពុងទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ ហើយសន្យាគោរពសិទ្ធិមនុស្សរបស់និយោជិតយើង។ យើងមានគោលបំណងគោរពលក្ខខណ្ឌការងាររបស់យើងឲ្យលើសពីស្តង់ដារអប្បបរមា។

### ២.១ ការទទួលខុសត្រូវផ្ទាល់ខ្លួន

យើងរំពឹងថា និយោជិតទាំងអស់របស់ BOS group នឹងគោរពតាមលក្ខខណ្ឌតម្រូវស្របច្បាប់ និងគោលការណ៍ណែនាំរបស់ក្រុមហ៊ុន អ្នកគ្រប់គ្រងទាំងអស់ត្រូវបានស្នើសុំឲ្យអនុវត្តមុខងារគំរូ។ សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗត្រូវតែបានគោរព និងការពារ។ នាយកប្រតិបត្តិទាំងអស់ត្រូវបានស្នើសុំឲ្យការពារការរំលោភបំពានក្រមសីលធម៌នេះណាមួយនៅក្នុងអង្គភាពរៀងៗខ្លួន។ និយោជិតម្នាក់ៗត្រូវតែទទួលបានដំបូន្មានច្បាស់លាស់ពីក្រមសីលធម៌នេះ។

### ២.២ ឱកាសស្មើគ្នា/ការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌/ កិច្ចការពារប្រឆាំងនឹងការរើសអើង

ក្នុងនាមជាក្រុមហ៊ុនដែលកំពុងប្រតិបត្តិការនៅទូទាំងពិភពលោក យើងសូមលើកកម្ពស់ភាពចម្រុះនៅក្នុងក្រុមហ៊ុន និងកិច្ចសហប្រតិបត្តិការជាមួយនិយោជិត និងដៃគូដែលមានវប្បធម៌ ផ្នត់គំនិត ឬសញ្ជាតិផ្សេងៗគ្នានិងជឿជាក់ថា កិច្ចសហការដែលទទួលបានជោគជ័យអាចធ្វើទៅបានដោយការគោរព និងការឲ្យតម្លៃគ្នាទៅវិញទៅមកប៉ុណ្ណោះ។

យើងមិនលើកលែងចំពោះការបង្កជាបញ្ហា ការរំលោភបំពាន ការបៀតបៀនផ្លូវភេទ ឬទម្រង់រើសអើងផ្សេងៗមកលើនិយោជិតរបស់យើងផ្អែកលើពូជសាសន៍ ឬសញ្ជាតិ ភេទ អាយុ ពណ៌សម្បុរ សាសនា ឬទស្សនៈពិភពលោក អត្តសញ្ញាណផ្លូវភេទ ពិការភាព មានជំងឺ ឬការមានផ្ទៃពោះ។

យើងនៅតែរក្សាឱកាសស្មើគ្នាដដែលទាំងក្នុងការស្វែងរកនិយោជិតថ្មី ទាំងក្នុងអំឡុងពេលទំនាក់ទំនងការងារ។

យើងមិនក្លែងបន្លំ ឬបោកបញ្ឆោតនិយោជិតដែលមានសក្តានុពលអំពីលក្ខណៈនៃការងារនោះទេ។ យើងមិនគិតថ្លៃជ្រើសរើសពីពួកគេទេ ហើយក៏មិនដែលលួចឯកសារអត្តសញ្ញាណរបស់ពួកគេដែរ។ នៅដំណាក់កាលដំបូងនៃដំណើរការជ្រើសរើសបុគ្គលិក អ្នកដាក់ពាក្យទទួលបានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរជាភាសាដែលពួកគេចេះ បញ្ជាក់យ៉ាងច្បាស់ និងស្មោះត្រង់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ។

### ២.៣ លក្ខខណ្ឌការងារត្រឹមត្រូវ

យើងមិនលើកលែងចំពោះពលកម្មដោយបង្ខំ ឬដោយចាប់បង្ខំក្នុងទម្រង់ណាមួយឡើយ។ អនុលោមតាមស្តង់ដារការងារស្នូលរបស់ ILO យើងសូមបដិសេធដាច់ខាតចំពោះការប្រើកម្លាំងពលកម្មដោយបង្ខំ ឬដោយចាប់បង្ខំខុសច្បាប់។

យើងមិនលើកលែងចំពោះពលកម្មកុមារក្នុងទម្រង់ណាមួយឡើយ។ អនុលោមតាមស្តង់ដារការងារស្នូលរបស់ ILO យើងអនុវត្តតាមអាយុអប្បបរមាសម្រាប់ការងារ និងបដិសេធដាច់ខាតចំពោះពលកម្មកុមារ។

បុគ្គលិករបស់យើងមានជម្រើសការងារដោយសេរី។ ពួកគេអាចបញ្ចប់ទំនាក់ទំនងការងាររបស់ពួកគេនៅពេលណាក៏បានស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា។

យើងប្រកាន់ខ្ជាប់នូវសេរីភាពក្នុងការបង្កើតសមាគម និងការទទួលស្គាល់ប្រកបដោយប្រសិទ្ធភាពនៃសិទ្ធិក្នុងការចរចាជាសមូហភាព និងធានាថា និយោជិតរបស់យើងអាចពិភាក្សាដោយបើកចំហអំពីលក្ខខណ្ឌការងារជាមួយអ្នកគ្រប់គ្រងដោយមិនភ័យខ្លាចពីគុណវិបត្តិ។ យើងគោរពសិទ្ធិរបស់និយោជិតយើងក្នុងការសហការ ចូលរួមសហជីព តែងតាំង និងជ្រើសរើសធ្វើជាតំណាង។

វប្បធម៌របស់យើងត្រូវបានសម្គាល់ដោយការជឿទុកចិត្ត និងកិច្ចសហការក្នុងន័យស្ថាបនាជាមួយតំណាងនិយោជិតរៀងៗខ្លួន។ គោលដៅរួមគឺត្រូវរក្សាកិច្ចសហប្រតិបត្តិការប្រកបដោយនិរន្តរភាពដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុន និងនិយោជិត។

សំណង និងអត្ថប្រយោជន៍សម្រាប់និយោជិតរបស់យើងអនុលោមតាមគោលការណ៍ជាមូលដ្ឋានទាក់ទងនឹងប្រាក់ឈ្នួលអប្បបរមា បទប្បញ្ញត្តិស្តីពីការងារថែមម៉ោងដែលអាចអនុវត្តបាន និងអត្ថប្រយោជន៍សង្គមតាមច្បាប់។ ម៉ោងធ្វើការ និងក្រៅម៉ោងធ្វើការរបស់យើងអនុវត្តជាអប្បបរមាតាមច្បាប់ជាធរមាន ស្តង់ដារឧស្សាហកម្ម ឬអនុសញ្ញាពាក់ព័ន្ធរបស់អង្គការ ILO ដែលបានកំណត់យ៉ាងតឹងរ៉ឹង ។

យើងអនុវត្តតាមបទបញ្ញាស្តីពីម៉ោងធ្វើការថ្នាក់ជាតិជាធរមាននៅទូទាំងពិភពលោក។ លើសពីនេះទៀត បទបញ្ញាស្តីពីម៉ោងធ្វើការរបស់យើងបរិយាយអំពីគោលការណ៍ជាធរមានទាក់ទងនឹងរយៈពេលសម្រាក ពេលទំនេរ វិស្សមកាល និងតុល្យភាពជីវិត ក៏ដូចជាថ្ងៃឈប់សម្រាកផ្សេងទៀតដែលអាចកើតមាន។ ម៉ោងធ្វើការរបស់យើងអាចរកបាននៅលើអ៊ីនត្រានែតទីតាំងរបស់ BOS ។

ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងគុណវុឌ្ឍិ គឺផ្អែកទៅលើតែការអនុវត្តការងាររបស់បុគ្គល សមត្ថភាពបុគ្គល និងភាពសក្តិសមផ្ទាល់ខ្លួនប៉ុណ្ណោះ។ យើងផ្តល់រង្វាន់ដល់និយោជិតរបស់យើងចំពោះការអនុវត្តការងារជាលក្ខណៈបុគ្គល ឬជាសមូហភាពស្របតាមគោលការណ៍ក្នុងស្រុក។

## ២.៤ កិច្ចគាំពារសុខភាព សុវត្ថិភាព និងបរិស្ថាននៅកន្លែងធ្វើការ

យើងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារជាធរមានទូទាំងពិភពលោក។

យើងក៏បានកំណត់ស្តង់ដារផ្ទាល់របស់យើងដើម្បីកែលម្អសុវត្ថិភាពការងារ និងកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ជាមួយប្រព័ន្ធគ្រប់គ្រងរបស់យើងសម្រាប់បរិស្ថាន សុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ (USGA) ដែលរាប់បញ្ចូលទាំងប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពយោងតាម ISO ៤៥០០១ និងប្រព័ន្ធគ្រប់គ្រងបរិស្ថាន យោងតាម ISO ១៤០០១។ ព័ត៌មានលម្អិតអំពី USGA អាចរកបាននៅលើអ៊ីនត្រានែតរបស់ BOS។

ដូច្នេះ យើងប្តេជ្ញាអនុវត្តតាមលក្ខខណ្ឌតម្រូវទាក់ទងនឹងសុវត្ថិភាពការងារខ្ពស់បំផុត ទោះបីជាលក្ខខណ្ឌតម្រូវទាបជាងអាចអនុញ្ញាតបាននៅក្នុងប្រទេសនីមួយៗក៏ដោយ។

យើងទាំងអស់គ្នាទទួលខុសត្រូវរួមគ្នាដើម្បីការពារប្រជាជន និងបរិស្ថាន។ និយោជិតរបស់យើងមានភារកិច្ចក្នុងការថែរក្សាកន្លែងធ្វើការរបស់ខ្លួនឲ្យមានរបៀបរៀបរយ និងមានសុវត្ថិភាព ដើម្បីការពារបរិស្ថាន និងប្រើប្រាស់ធនធានដែលមានស្រាប់ដោយសន្សំសំចៃ និងមានប្រយោជន៍។ ប្រសិនបើមានការប្រែប្រួលណាមួយ ត្រូវរាយការណ៍ទៅអ្នកគ្រប់គ្រង។

## ២.៥ ការចៀសវាងនូវទំនាស់ផលប្រយោជន៍

យើងធានាថា ផលប្រយោជន៍របស់និយោជិតស្របតាមផលប្រយោជន៍របស់ក្រុមហ៊ុន។ ដូច្នេះ និយោជិតម្នាក់ៗគួរចៀសវាងស្ថានភាពដែលនាំឲ្យកើតមានទំនាស់ដោយប្រការណាមួយ រវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងក្រុមហ៊ុន។ ស្ថានភាពទាំងនេះអាចកើតឡើង ឧទាហរណ៍ក្នុងករណីមានសកម្មភាពទាំងឡាយ ឬការវិនិយោគទុនរួមគ្នាជាមួយក្រុមហ៊ុន ឬអាជីវកម្មផ្សេងទៀតជាមួយមិត្តភក្តិ ឬសាច់ញាតិ។ គួរចៀសវាងទំនាក់ទំនងអាជីវកម្មបែបនេះ ហើយប្រធានគ្រប់គ្រងម្នាក់ៗគួរតែទទួលដំណឹងភ្លាមៗ។ ការងារបន្ទាប់បន្សំទាំងឡាយដែលទទួលបានប្រាក់ឈ្នួលត្រូវមានការឯកភាពជាលាយលក្ខណ៍អក្សរពីប្រធានគ្រប់គ្រងម្នាក់ៗ និង/ឬ ផ្នែកធនធានមនុស្ស។

## ២.៦ ការការពារទ្រព្យសម្បត្តិក្រុមហ៊ុន

យើងរំពឹងថា និយោជិតរបស់យើងនឹងការពារទ្រព្យសកម្មរូបិយ និងទ្រព្យសកម្មអរូបិយដោយការយកចិត្តទុកដាក់។ ទ្រព្យសកម្មទាំងនេះ រួមមាន អគារ យានយន្ត សម្ភារៈការិយាល័យ ក៏ដូចជាចំណេះធ្វើ ប្រកាសនីយបត្រតក្កកម្ម នវានុវត្តន៍ បច្ចេកវិទ្យា និងព័ត៌មានដ៏មានតម្លៃផ្សេងទៀតសម្រាប់ BOS Group ដែលត្រូវការពារ។ នវានុវត្តន៍ និងសមត្ថភាពរបស់យើងគួរត្រូវបានការពារមិនត្រឹមតែពីចោរកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការពារពីការលួចចម្លងផងដែរ។

គ្រឿងបរិក្ខារ និងឧបករណ៍ទាំងអស់អាចប្រើប្រាស់សម្រាប់តែគោលបំណងឯកជនដោយមានការអនុញ្ញាតពិសេសជាមុនប៉ុណ្ណោះ។

## ២.៧ សុវត្ថិភាពព័ត៌មាន និងការការពារទិន្នន័យ

យើងតម្រូវឲ្យនិយោជិតរបស់យើងរក្សាទិន្នន័យ ព័ត៌មាន នវានុវត្តន៍ និងចំណេះធ្វើជាការសម្ងាត់ និងប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មរបស់ BOS តែប៉ុណ្ណោះ។ ចំណុចទាំងនេះគឺជាមូលដ្ឋានសម្រាប់ភាពជោគជ័យប្រកបដោយចីរភាពរបស់យើង ហើយមិនត្រូវលាតត្រដាង ឬផ្តល់ជូនតតិយជនទោះក្នុងកាលៈទេសៈណាក៏ដោយ។ លក្ខខណ្ឌដដែលនេះអនុវត្តចំពោះទិន្នន័យផ្ទាល់ខ្លួនទាំងអស់ចំពោះនិយោជិតរបស់ BOS Group។

យើងរក្សាស្តង់ដារខ្ពស់នៃការការពារទិន្នន័យដើម្បីការពារសិទ្ធិឯកជនរបស់និយោជិត និងអតិថិជនរបស់យើងទាក់ទងនឹងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគាត់។ ជាពិសេស យើងអនុវត្តតាមស្តង់ដារការពារទិន្នន័យរបស់ប្រទេសអាល្លឺម៉ង់ និងអ៊ឺរ៉ុប ដើម្បីធានាបាននូវការគោរពសិទ្ធិផ្ទាល់ខ្លួនដ៏ប្រសើរបំផុតនៅទូទាំងពិភពលោក។ ការការពារទិន្នន័យរបស់យើងធានាថា ការប្រើប្រាស់ទិន្នន័យ

ផ្ទាល់ខ្លួនអនុលោមតាមច្បាប់ និងថាសិទ្ធិរបស់បុគ្គលម្នាក់ៗត្រូវបានការពារ។

### ២.៨ សិទ្ធិជនជាតិភាគតិច និងជនជាតិដើមភាគតិច / សិទ្ធិដីធ្លី

យើងគោរព និងប្រតិបត្តិសិទ្ធិរបស់សហគមន៍មូលដ្ឋានចំពោះជីវភាពរស់នៅគ្រប់គ្រាន់ ការអប់រំ ការងារ សកម្មភាពសង្គម និងសិទ្ធិទទួលបានដោយសេរី ការយល់ព្រមជាមុន និងជូនដំណឹង (FPIC) ចំពោះការអភិវឌ្ឍដែលប៉ះពាល់ដល់ពួកគេ និងដីធ្លីដែលពួកគេរស់នៅ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះវត្តមានរបស់ក្រុមងាយរងគ្រោះ។

ប្រសិនបើការប្រើប្រាស់កងកម្លាំងសន្តិសុខអាចបណ្តាលឲ្យមានការរំលោភសិទ្ធិមនុស្ស ដោយសារតែខ្វះការបណ្តុះបណ្តាល ឬការគ្រប់គ្រងលើផ្នែកណាមួយរបស់ក្រុមហ៊ុន នោះយើងមិនជួល ឬប្រើប្រាស់កងកម្លាំងសន្តិសុខឯកជន ឬសាធារណៈដើម្បីការពារគម្រោងអាជីវកម្មឡើយ។

យើងចៀសវាងការបណ្តេញចេញដោយបង្ខំ និងការដកហូតដីធ្លី ព្រៃឈើ និងទឹក នៅពេលទទួលបានការអភិវឌ្ឍ ឬប្រើប្រាស់ដី ព្រៃឈើ និងទឹក។

## ៣. អន្តរកម្មជាមួយដៃគូអាជីវកម្ម

យើងខិតខំប្រឹងប្រែងធ្វើជាដៃគូដែលអាចទុកចិត្តបាន ទាំងសហការជាមួយអតិថិជនរបស់យើង អ្នកផ្គត់ផ្គង់ និងដៃគូអាជីវកម្ម ក៏ដូចជានៅក្នុងក្រុមហ៊ុនរបស់យើង។ ក្រៅពីសមត្ថភាព ថាមពលនវានុវត្តន៍ និងគុណភាពនៃផលិតផលរបស់យើង ក៏តម្រូវឲ្យមានការប្រាស្រ័យទាក់ទងដោយបើកចំហ ភាពស្មោះត្រង់ និងតម្លាភាព ហើយយើងនៅរក្សាការសន្យារបស់យើង និងទំនាក់ទំនងក្នុងកិច្ចសន្យា។

### ៣.១ ការជ្រើសរើសដៃគូអាជីវកម្ម

ការជ្រើសរើសដៃគូអាជីវកម្មរបស់យើង (ឧ. អ្នកផ្គត់ផ្គង់ អ្នកផ្តល់សេវា អ្នកតំណាងផ្នែកលក់ អ្នកចែកចាយ ដៃគូគម្រោង អ្នកប្រឹក្សាយោបល់) ត្រូវបានធ្វើឡើងដោយមិនលម្អៀងផ្អែកលើការផ្តល់ជូនដែលត្រូវបានវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យគោលបំណងដែលបានកំណត់ពីមុន។ យើងបដិសេធរាល់ការអនុគ្រោះ ឬការធ្វើឲ្យខូចប្រយោជន៍ដោយអត្តនោម័ត។

យើងរំពឹងថាដៃគូអាជីវកម្មរបស់យើងនៅទូទាំងពិភពលោកនឹងគោរពគោលការណ៍ដែលបានបង្ហាញនៅក្នុងក្រមសីលធម៌របស់យើង ដូចជាការគោរពចំពោះមនុស្ស និងបរិស្ថាន លក្ខខណ្ឌតម្រូវនៃការអនុលោមតាមច្បាប់យ៉ាងតឹងរ៉ឹង ការលុបបំបាត់អំពើពុករលួយ និងសុចរិតភាពក្នុងការប្រកួតប្រជែង និងធ្វើសកម្មភាពស្របតាមរយៈពេលនៃសកម្មភាពអាជីវកម្មរបស់ពួកគេ។ ការងារនេះអាចធ្វើបានដោយការប្តេជ្ញាចិត្តក្នុងកិច្ចសន្យាចំពោះស្តង់ដារនិរន្តរភាពរបស់យើងសម្រាប់អ្នកផ្គត់ផ្គង់ ឬដោយការផ្តល់នូវភស្តុតាងនៃក្រមសីលធម៌ដែលបានធ្វើសវនកម្មជាមុន ដែលរួមមានគោលការណ៍អាជីវកម្មដែលអាចប្រៀបធៀបបាន។

ព័ត៌មានលម្អិតបន្ថែមត្រូវបានគ្រប់គ្រងនៅក្នុងក្រមសីលធម៌របស់ BOS - ស្តង់ដារនិរន្តរភាពសម្រាប់អ្នកផ្គត់ផ្គង់។

## ៣.២ ការប្រកួតប្រជែងដោយយុត្តិធម៌ និងនិរន្តរភាព

យើងអនុវត្តតាមវិធាននៃការប្រកួតប្រជែងដោយយុត្តិធម៌ និងនិរន្តរភាព និងគាំទ្រគំនិតនៃទីផ្សារសេរី និងពាណិជ្ជកម្មដោយយុត្តិធម៌។ ហាមប្រព្រឹត្តអំពើអយុត្តិធម៌។

សកម្មភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់យើងត្រូវបានត្រួតពិនិត្យផ្ទៃក្នុងជាប្រចាំ និងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនសវនកម្ម និងអាជ្ញាធរធនាគារ និងត្រួតពិនិត្យហិរញ្ញវត្ថុរៀងៗខ្លួន។

យើងប្រកាន់ខ្ជាប់នូវវិធានផ្សេងៗអំពីពាណិជ្ជកម្មបរទេស ពន្ធគយ ក្នុងសកម្មភាពជាសាកលរបស់យើងដោយគោរពតាមការដាក់ទណ្ឌកម្មសេដ្ឋកិច្ចជាចាំបាច់គ្រប់ពេលវេលា និងដឹងពីការទទួលខុសត្រូវក្នុងសង្គមរបស់យើងក្នុងការបំពេញកាតព្វកិច្ចពន្ធគយរបស់យើង។

## ៣.៣ ធនធានរ៉ែមានទំនាស់

យើងយកចិត្តទុកដាក់ជាពិសេសក្នុងការចងក្រងឯកសារខ្សែសង្វាក់ផ្គត់ផ្គង់ ដោយតម្លាភាពសម្រាប់ធនធានរ៉ែមានទំនាស់ដោយអនុលោមតាមបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុបឆ្នាំ ២០១៧/៨២១ និងសហរដ្ឋអាមេរិក Dodd-Frank ផ្នែកទី១៥០២។

## ៣.៤ ការប្រកួតប្រជែង និងច្បាប់ប្រកួតប្រជែងដោយយុត្តិធម៌

យើងរំពឹងថា និយោជិតគ្រប់រូបត្រូវប្រកាន់ខ្ជាប់នូវគំនិតនៃការប្រកួតប្រជែងប្រកបដោយយុត្តិធម៌ និងអនុវត្តតាមច្បាប់ប្រកួតប្រជែងរបស់ប្រទេសទាំងអស់ដែល BOS ធ្វើអាជីវកម្ម ដោយរួមបញ្ចូលទាំងអាជីវកម្មនៅក្នុងប្រទេសដែលជាប់ទណ្ឌកម្មសេដ្ឋកិច្ច។ ដូច្នេះ មិនអាចអនុញ្ញាតឲ្យចុះកិច្ចព្រមព្រៀងដែលមានអ្នកប្រកួតប្រជែងដែលអាចមានឥទ្ធិពលដល់ការប្រកួតប្រជែងនេះបានឡើយ។ លក្ខខណ្ឌដដែលនេះអនុវត្តចំពោះការដោះដូរព័ត៌មានទាក់ទងនឹងតម្លៃ លក្ខខណ្ឌ សមត្ថភាព ភាគហ៊ុនលើទីផ្សារ កម្រិតអនុគ្រោះ ថ្លៃដើម ក៏ដូចជា ព័ត៌មានលម្អិតស្ដីពីការផ្ដល់ជូន។

## ៣.៥ ការជូនកាដូ និងអត្ថប្រយោជន៍

យើងនឹងមិនលើកលែងចំពោះអំពើពុករលួយ ការសូកប៉ាន់ ការជំរិតទារប្រាក់ ឬការកិបកេងប្រភេទណាមួយបានឡើយ។ រាល់សកម្មភាពរបស់យើងត្រូវបានអនុវត្តប្រកបដោយការទទួលខុសត្រូវ និងភាពស្មោះត្រង់។ និយោជិតណាមួយដែលអាចរងឥទ្ធិពលដោយសារអាកប្បកិរិយាអសីលធម៌ពីអតិថិជន ឬអ្នកផ្គត់ផ្គង់ ឬអ្នកដែលមានឥទ្ធិពលលើពួកគេ នឹងត្រូវទទួលខុសត្រូវ និងរងការដាក់ពិន័យ។ គ្មានប្រាក់រង្វាន់អាចត្រូវបានផ្សារភ្ជាប់ទៅនឹងតម្រូវការ ឬការផ្ដល់ការពិចារណានោះទេ។

និយោជិតរបស់យើងមិនត្រូវបានអនុញ្ញាតឲ្យទទួលយករង្វាន់ ឬកាដូ ពាក់ព័ន្ធនឹងសកម្មភាពវិជ្ជាជីវៈរបស់ខ្លួនឡើយ។ ប្រសិនបើមានគេជូនរង្វាន់ ឬកាដូដល់និយោជិតពាក់ព័ន្ធនឹងសកម្មភាពវិជ្ជាជីវៈរបស់ខ្លួនត្រូវជូនដំណឹងទៅនិយោជកភ្លាមៗ។ ការជូនកាដូជាប្រាក់មិនអាចទទួលយកបានឡើយ។

## ៣.៦ អំណោយ

អង្គការ និងស្ថាប័នផ្សេងៗកំពុងមករកយើងដើម្បីសុំអំណោយ។ រាល់អំណោយទាំងឡាយក៏ត្រូវមានការឯកភាពពីថ្នាក់លើដែរ។ ត្រូវស្គាល់ និងយល់ដឹងអំពីអ្នកទទួលនិងគោលបំណងនៃអំណោយនោះ។ ត្រូវគោរពគោលការណ៍មិនអាត្មានិយម។

## ៤. ភាពអនុលោម និងការអនុវត្តក្រមសីលធម៌

ក្រមសីលធម៌របស់យើងត្រូវបានផ្សព្វផ្សាយដល់បុគ្គលិកទាំងអស់។ យើងរំពឹងថា និយោជិត BOS ទាំងអស់ នឹងគោរពតាមបទបញ្ញា និងគោលការណ៍ណែនាំរបស់ក្រុមហ៊ុន និងបំពេញការងារប្រកបដោយវិជ្ជាជីវៈ។

### ៤.១ ការទទួលខុសត្រូវ

អ្នកគ្រប់គ្រងរបស់យើងមានកាតព្វកិច្ចជូនដំណឹងដល់និយោជិតរបស់ពួកគាត់អំពីខ្លឹមសារ និងសារសំខាន់នៃក្រមសីលធម៌នេះ និងណែនាំ និងគាំទ្រពួកគាត់ក្នុងការអនុវត្តតាមក្រមសីលធម៌នេះក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់។

និយោជិតគ្រប់រូបរបស់ BOS Group តម្រូវឲ្យគោរពតាមក្រមសីលធម៌របស់យើង និងធ្វើឲ្យគោលការណ៍នៃក្រមសីលធម៌នេះក្លាយជាស្តង់ដារចងភ្ជាប់កាតព្វកិច្ចក្នុងការអនុវត្តភារកិច្ចប្រចាំថ្ងៃ។

ចំពោះគោលបំណងនេះ ជាការចាំបាច់ដែលត្រូវជូនដំណឹងដល់នរណាម្នាក់យ៉ាងសកម្ម និងជាបន្តអំពីតម្រូវការដែលមានស្រាប់ និងចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលបានផ្តល់ជូន។

### ៤.២ ការរំលោភបំពាន

ការរំលោភបំពានណាមួយអាចនាំឲ្យមានផលវិបាកធ្ងន់ធ្ងរដល់ក្រុមហ៊ុនទាំងមូល និងដោយផ្អែកលើភាពធ្ងន់ធ្ងរអាចឈានទៅរកការអនុវត្តច្បាប់ការងារ ឬច្បាប់ព្រហ្មទណ្ឌ។

ប៉ុន្តែ យើងជឿជាក់ថា និយោជិតទាំងអស់របស់យើងធ្វើការសម្រេចចិត្តត្រឹមត្រូវ និងរាយការណ៍អំពីការរំលោភបំពានណាមួយទៅថ្នាក់លើរបស់ខ្លួន ដើម្បីដោះស្រាយករណីរំលោភបំពាននោះតាមមូលដ្ឋានក្នុងការពិភាក្សាដើម្បីស្ថាបនា។ យ៉ាងណាក៏ដោយ អាចនឹងមានករណីមួយចំនួន ជាពិសេសប្រសិនបើវាពាក់ព័ន្ធនឹងការអនុវត្តអាជីវកម្មខុសច្បាប់ ដើម្បីដោះស្រាយស្ថានភាព ក្រៅបរិយាកាសការងារបន្ទាន់។ និយោជិត និងតតិយជនអាចទាក់ទងបុគ្គលទំនាក់ទំនងខាងក្រោម៖

- អ្នកគ្រប់គ្រងរបស់អ្នក
- គណៈគ្រប់គ្រងជាន់ខ្ពស់
- ផ្នែកធនធានមនុស្ស ហិរញ្ញវត្ថុ ឬអ្នកតំណាងនិយោជិតរបស់អ្នក ប្រសិនបើអាចធ្វើទៅបាន
- បុគ្គលទំនាក់ទំនងដែលមានឈ្មោះនៅក្នុងក្រមសីលធម៌របស់ BOS

និយោជិតដែលរាយការណ៍ដោយសុទ្ធចិត្តអំពីការប្រព្រឹត្តខុសជាក់ស្តែង ឬដែលត្រូវបានគេដឹង មិនត្រូវទទួលគុណវិបត្តិណាមួយដោយសាររឿងដែលខ្លួនបានប្រព្រឹត្តឡើយ។ យោងតាមដំណើរការនៃការរាយការណ៍នេះ BOS នឹងរក្សាអត្តសញ្ញាណរបស់និយោជិតនោះជាការសម្ងាត់ តាមដែលអាចធ្វើទៅបាន និងមានការអនុញ្ញាតដោយច្បាប់។

### ៤.៣ បុគ្គលទំនាក់ទំនង

ប្រសិនបើលោកអ្នកមិនអាចសម្តែងចេញនូវក្តីកង្វល់ ការគិតទុកក្នុងចិត្ត ឬរឿងរ៉ាវដែលចង់និយាយនៅក្នុងមូលដ្ឋាន ឬលោកអ្នកមិនទទួលបានការគាំទ្រសមស្រប លោកអ្នកអាចទំនាក់ទំនងទៅប្រធានផ្នែកធនធានមនុស្សអន្តរជាតិ តាមរយៈទូរសព្ទលេខ៖ ៤៩ ៧១១ ៩៣៦០ ១៣៤៦ និង/ឬតាមរយៈអ៊ីមែល៖ hinweisgeben@bos.de ឬអាចទំនាក់ទំនងផ្ទាល់ទៅប្រធានក្រុមហ៊ុនតែម្តង។

បុគ្គលទំនាក់ទំនងខាងក្នុង៖
ប្រធានផ្នែកធនធានមនុស្សអន្តរជាតិ
BOS GmbH & Co. KG
Ernst-Heinkel-Str. ២
D-៧៣៧៦០ អូសទ្វីឌើន
ប្រទេសអាល្លឺម៉ង់
ទូរសព្ទលេខ៖ +៤៩ (0) ៧១១ ៩៣៦០-១៣៤៦
អ៊ីមែល៖ hinweisgeben@bos.de

បុគ្គលទំនាក់ទំនងខាងក្រៅ៖
អនុប្រធានប្រតិបត្តិ ខ្សែសង្វាក់ផ្គត់ផ្គង់
BOS GmbH & Co. KG
Ernst-Heinkel-Str. ២
D-៧៣៧៦០ អូសទ្វីឌើន
ប្រទេសអាល្លឺម៉ង់
ទូរសព្ទលេខ៖ +៤៩-(0)៧១១-៩៣៦០-១៦៤៦
អ៊ីមែល៖ hint@bos.de

### ៤.៤ ការស៊ើបអង្កេត និងការរាយការណ៍

បញ្ហាដែលបានរាយការណ៍ត្រូវបានស៊ើបអង្កេត និងត្រូវចាត់វិធានការជាចាំបាច់។ ក្នុងករណីនិយោជិតណាម្នាក់រំលោភបំពានលើគោលការណ៍ ដូចមានចែងនៅក្នុងក្រមសីលធម៌នេះ និយោជិតនោះត្រូវរងការដាក់ពិន័យក្រោមច្បាប់ស្តីពីការងារ ដោយអនុលោមតាមច្បាប់ជាតិ។

ការស៊ើបអង្កេតពាក់ព័ន្ធនឹងករណីរំលោភបំពានលើក្រមសីលធម៌នឹងត្រូវធ្វើឡើងជាការសម្ងាត់បំផុត ដោយការពារភាគីដែលរាយការណ៍ និងពិចារណាលើច្បាប់ស្តីពីការការពារទិន្នន័យ។

## ៥. ប្រការចុងក្រោយ

ក្រមសីលធម៌របស់ BOS Group ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ គ្មានបុគ្គលណាម្នាក់អាចមកទាមទារ ឬមិនអាចមានការទាមទារពីតតិយជនណាមួយចេញពីក្រមសីលធម៌នេះបានឡើយ។ មានតែក្រមសីលធម៌ដែលមានសំណៅជាភាសាអាល្លឺម៉ង់ប៉ុណ្ណោះទើបចងភ្ជាប់កាតព្វកិច្ចបាន។